ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

# សារជូនពរ

## សូមគោរពជូន

## សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា

**សម្តេចកត្តិព្រឹទ្ធបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់ !**

ក្នុងឱកាសរំលឹកខួបអនុស្សាវរីយ៍លើកទី១០៦ ទិវាអន្តរជាតិនារី៨មីនា ខ្ញុំបាទ ភរិយា ព្រមទាំងបុត្រ និងតាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង ពលទាហាន ទាំងអស់ នៃកងយោធពលខេមរភូមិន្ទ សូមអនុញ្ញាតសម្តែងនូវអំណរសាទរ និងសូមគោរពជូនពរ **សម្តេចកត្តិព្រឹទ្ធបណ្ឌិត** សូមមានសុខភាពល្អបរិបូរណ៍ ជន្មាយុយឺនយូរ ប្រាជ្ញាឈ្លាសវៃ ដើម្បីសម្រេចបានជោគជ័យថ្មីៗថែមទៀត ក្នុងគ្រប់ភារកិច្ច ជាពិសេសក្នុងការដឹកនាំចលនាមនុស្សធម៌នៃកាកបាទក្រហមកម្ពុជា។

ក្នុងទិវាមហាប្រសើរនេះ យើងខ្ញុំទាំងអស់គ្នាសូមសម្តែងនូវគុណធម៌ដ៏ជ្រាលជ្រៅ និងសូមកោត សរសើរប្រកបដោយភក្តីភាពដ៏ស្មោះអស់ពីដួងចិត្ត ចំពោះគំរូវីរភាពដ៏ឆ្នើម ដែល **សម្តេចកត្តិព្រឹទ្ធបណ្ឌិត** សម្រេចបានក្នុងរយៈពេលកន្លងមក ក្នុងបេសកកម្មមនុស្សធម៌ ជួយចែករំលែក និងដោះស្រាយរាល់ទុក្ខ លំបាករបស់កងទ័ព ក៏ដូចជាប្រជាពលរដ្ឋទូទៅ ជាពិសេស **សម្តេចកត្តិព្រឹទ្ធបណ្ឌិត** គឺជាគំរូនៃស្ត្រីខ្មែរ ដែលបានបំពេញជាឧត្តមភរិយា នៃ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រកម្ពុជា ជាមាតាប្រកបដោយព្រហ្មវិហារធម៌ និងជាមាតាសង្គ្រោះនៅគ្រប់កាលៈទេសៈ។

ជាថ្មីម្តងទៀត ក្នុងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង ពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ ខ្ញុំសូមប្រសិទ្ធពរជ័យសិរីសួស្តី ជ័យមង្គល វិបុលសុខ បវរ មហាប្រសើរថ្លៃថ្លា ជូន**សម្តេចកត្តិព្រឹទ្ធបណ្ឌិត** និង **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងបុត្រាបុត្រី និងចៅប្រុសចៅស្រី សូមបានប្រកបដោយពុទ្ធ ពរទាំងបួន ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចកត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា ជាទីគោរពដ៏ ខ្ពង់ខ្ពស់ មេត្តាទទួលនូវគារវភក្តីភាពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ បាញ់**

វិថីហ្សកឌីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារៈ ០២៣ ៨៨៣ ២៧៤ អ៊ីមែលៈ generalsec@mod.gov.kh